# សុន្ទរកថា របស់លោកស្រីឧត្តមស្នងការ
# ជូនចំពោះរដ្ឋសភាកម្ពុជា

ថ្ងៃទី ២១ ខែសីហា ឆ្នាំ ២០០២

**សម្តេច ឯកឧត្តម លោកជំទាវ សមាជិករដ្ឋសភា**

ខ្ញុំសូមចាប់ផ្តើម ដោយសំដែងអំណរគុណចំពោះសម្តេច ឯកឧត្តម លោកជំទាវ ដែលបានអញ្ជើញខ្ញុំឱ្យមកនិយាយទៅកាន់សម្តេច ឯកឧត្តម លោកជំទាវ នៅថ្ងៃនេះ ។ ខ្ញុំមានសេចក្តីរីករាយ និងមានកិត្តិយសណាស់ ដែលមានឱកាសថ្លែងទៅកាន់សម្តេច ឯកឧត្តម លោកជំទាវ ហើយតាមរយៈសម្តេច ឯកឧត្តម លោកជំទាវ ទៅកាន់ប្រជាពលរដ្ឋកម្ពុជា ។

ខ្ញុំបានមកបំពេញទស្សនៈកិច្ចនៅប្រទេសកម្ពុជា ជាលើកទី ១ ក្នុងឋានៈជាឧត្តមស្នងការ នៅខែមករា ឆ្នាំ ១៩៩៨ ។ ការព្រួយបារម្ភរបស់ជាតិនៅពេលនោះ គឺការខិតចូលមកកាន់តែជិតនៃការបោះឆ្នោតរដ្ឋសភានេះ ហើយនឹងសារៈសំខាន់នៃការបោះឆ្នោតសេរី និងត្រឹមត្រូវ ។ ខ្ញុំមានសេចក្តីបារម្ភជាពិសេសថា ការបោះឆ្នោតជ្រើសរើសសមាជិកនៃអង្គការដ៏ឧត្តមនេះ នៅក្នុងរដូវក្តៅនៃឆ្នាំនោះ ត្រូវតែធ្វើឡើងក្នុងលក្ខណៈ សេរី និងត្រឹមត្រូវ ។

ខ្ញុំមានកិត្តិយសបានមកថ្លែងជូនសម្តេច ឯកឧត្តម លោកជំទាវ នៅថ្ងៃនេះ ក្នុងឱកាសដ៏សំខាន់មួយទៀត ក្នុងការអភិវឌ្ឍន៍ប្រជាធិបតេយ្យនៃប្រទេសកម្ពុជា នៅពេលរដ្ឋសភាពិនិត្យវិសោធនកម្មលើច្បាប់ដែលនឹងអនុម័តការបោះឆ្នោតជាតិឆ្នាំ ២០០៣ ខាងមុខនេះ ។ ខ្ញុំដឹងថា មានការពិភាក្សាដ៏សំខាន់ និងមានទស្សនៈផ្សេង ៗ គ្នា ស្តីពីវិស័យជាច្រើននៃច្បាប់នេះ និងទទ្ទឹងថានឹងមានការវិវត្តន៍នៃច្បាប់ និងបទបញ្ជានានា ដែលជួយដោះស្រាយការព្រួយបារម្ភជាគន្លឹះនានា ដើម្បីជោគជ័យនៃការបោះឆ្នោតទាំងនេះ ។ ទាំងនេះ រួមមានជំនឿជាសាធារណៈ ទៅលើស្ថាប័នបោះឆ្នោត សេរីភាពក្នុងការសំដែងមតិ និងការទទួលបានការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយពតិមានសំរាប់គណបក្សនយោបាយទាំងអស់ ការដាក់ឱ្យអនុវត្តន៍ច្បាប់បោះឆ្នោតប្រកបដោយប្រសិទ្ធភាព ការដោះស្រាយដោយត្រឹមត្រូវ និងដោយសន្តិភាពនូវជម្លោះនានា និងលទ្ធផលដែលឆ្លុះបញ្ចាំងដោយត្រឹមត្រូវ នៃឆន្ទៈរបស់ប្រជាពលរដ្ឋកម្ពុជា ។

លើសពីនេះទៅទៀត គន្លឹះនៃជោគជ័យនៃច្បាប់ណាមួយ គឺកិច្ចដំណើរការពិគ្រោះយោបល់គ្នា ក្នុងចំណោមគណបក្សនយោបាយទាំងអស់ អង្គការសង្គមស៊ីវិលនានា និងសាធារណៈជនជាទូទៅ ។ ខ្ញុំមិនអាចថ្លែងនូវអ្វីខុសពីការពិត អំពីសារៈសំខាន់នៃការសាកសួរយោបល់ជាសាធារណៈ ចំពោះកិច្ចដំណើរការប្រជាធិបតេយ្យដ៏ត្រឹមត្រូវមួយបានឡើយ ។ ខ្ញុំសូមអនុញ្ញាតសំដែងសេចក្ដីសង្ឃឹមថា សម្ដេច ឯកឧត្ដម លោកជំទាវ និងប្រជាពលរដ្ឋកម្ពុជា ឥឡូវកំពុងស្ថិតនៅលើផ្លូវឆ្ពោះទៅកាន់សង្គមមួយ ដែលរដ្ឋាភិបាលមានការទទួលការខុសត្រូវ ប្រជាធិបតេយ្យ និងតំណាង នឹងត្រូវបានបង្កើតឡើងជាដាច់ខាត ។

ដូចសម្ដេច ឯកឧត្ដម លោកជំទាវ បានទ្រង់ជ្រាប និងបានជ្រាបទាំងអស់គ្នាស្រាប់មកហើយថា ការនេះមិនមែនសុទ្ធតែជាសភាពការណ៍ដែលកើតមានជានិច្ចកាល នៅក្នុងប្រទេសរបស់សម្ដេច ឯកឧត្ដម លោកជំទាវ នោះទេ ។ ប្រទេសកម្ពុជាបានរងការឈឺចាប់យ៉ាងខ្លាំងបំផុត ហើយស្លាមរបួសនៃជម្លោះ អំពើហឹង្សា និងការបង្ក្រាប រយៈពេល ៣០ ឆ្នាំ មិនងាយនឹងធ្វើឱ្យសះស្បើយបានឡើយ ។ ការនេះត្រូវការឆន្ទៈនយោបាយខ្លាំងក្លា និងមិនដាច់រយៈ ហើយនឹងការខិតខំ ( ការអត់ធ្មត់ ) យ៉ាងខ្លាំងមហិមា ដើម្បីដាក់បទពិសោធន៏នេះឱ្យនៅពីក្រោយខ្នងសម្ដេច ឯកឧត្ដម លោកជំទាវ ដើម្បីយកជំនះលើកេរ្តិ៍ដំណែលនេះ និងដើម្បីដោះស្រាយបញ្ហាបច្ចុប្បន្ន និងអនាគត ។ ប៉ុន្តែការនេះ អាច និងត្រូវតែធ្វើឱ្យបាន ។

អង្គការសហប្រជាជាតិ បានដើរតួនាទីសំខាន់មួយ ក្នុងការជួយប្រទេសកម្ពុជា ក្នុងកិច្ចខិតខំរបស់ខ្លួន ដើម្បីបង្កើតស្ថាប័នប្រជាធិបតេយ្យនានា លើមូលដ្ឋានមុឹងម៉ាត់មួយ ។ តួនាទីរបស់អង្គការអង្គការសហប្រជាជាតិនានា នៅក្នុងប្រទេសកម្ពុជា បានប្រែប្រួលទៅតាមពេលវេលា ដោយជនកម្ពុជាខ្លួនឯង និងរដ្ឋាភិបាលរបស់ពួកគេ បានទទួលយកការទទួលខុសត្រូវនៃអធិបតេយ្យភាពរបស់ខ្លួនហើយ ។ នេះគឺជាអ្វីដែលត្រូវតែមាន ពោលគឺរដ្ឋាភិបាលជ្រើសរើសឡើងដោយប្រជាធិបតេយ្យ ទទួលខុសត្រូវចំពោះប្រជាពលរដ្ឋនៃប្រទេសជាតិ ដើម្បីធានាថា សិទ្ធិជាមូលដ្ឋានរបស់ពួកគេត្រូវបានគោរពដោយពេញលេញ ។

វត្តមាននៅក្នុងប្រទេសកម្ពុជា នៃការិយាល័យសិទ្ធិមនុស្សអង្គការសហប្រជាជាតិរបស់យើងខ្ញុំ ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស ក៏បានបង្កើតឡើង ដោយឆ្លុះបញ្ចាំងមិនត្រឹមតែការប្រែប្រួលនៃកាលៈទេសៈរបស់ប្រទេសនេះប៉ុណ្ណោះទេ តែក៏ដោយសារៈសំខាន់ដែលចេះតែកើនឡើង ដែលសកលលោកឱ្យទម្ងន់ទៅលើការគោរពសិទ្ធិមនុស្សដោយពេញលេញ ។

នៅក្នុងប្រទេសកម្ពុជា វត្តមានរបស់យើងខ្ញុំមិនមែនមានតែការិយាល័យយើងខ្ញុំប៉ុណ្ណោះទេ តែក៏មានតំណាងពិសេសរបស់អគ្គលេខាធិការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជាផងដែរ ពោលគឺលោក ប៉េតឺរ លយប្រែលតឺ ដែលរាយការណ៍ជូនអគ្គលេខាធិការ គណៈកម្មការសិទ្ធិមនុស្ស និងមហាសន្និបាត ។ តាមរយៈយន្តកម្មទាំងនេះ យើងខ្ញុំតាមដានការវិវត្តន៍សិទ្ធិមនុស្សនៅក្នុងប្រទេសនេះដោយជិតស្និទ្ធ ទាំងនៅក្នុងទីក្រុងហ្សឺណែវ ទាំងនៅក្នុងទីក្រុងញូវយ៉ក ។

ខ្ញុំមានសេចក្តីពេញចិត្តដោយបានចុះហត្ថលេខា នៅក្នុងខែកុម្ភៈឆ្នាំនេះ លើអនុស្សរណៈថ្មីមួយ ជាមួយរាជរដ្ឋាភិបាលកម្ពុជា ពន្យារពេលកម្មវិធីនៃកិច្ចសហប្រតិបត្តិការបច្ចេកទេសរបស់យើងខ្ញុំ ស្តីពីសិទ្ធិមនុស្សសំរាប់រយៈពេល ២ ឆ្នាំ តទៅមុខទៀត ។ ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស នឹងបន្តផ្តល់ជំនួយ ដើម្បីបង្កើត និងពង្រឹងស្ថាប័ននានា ដើម្បីការពារ និងជំរុញការគោរពសិទ្ធិមនុស្ស ។ សកម្មភាពនឹងបន្តធ្វើតទៅទៀត ដើម្បីតម្រង់ឆ្ពោះទៅការកែទម្រង់ប្រព័ន្ធយុត្តិធម៌ និងច្បាប់ ក៏ដូចជាការប្រយុទ្ធប្រឆាំងនិទ្ទណ្ឌភាពដែរ ។ ការយកចិត្តទុកដាក់ នឹងផ្តល់ទៅលើសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយយកចិត្តទុកដាក់ជាពិសេសទៅលើបញ្ហាដីធ្លី និងលំនៅដ្ឋាន។ យើងនឹងបន្តជួយរដ្ឋាភិបាលក្នុងការធានាការពារសិទ្ធិមនុស្សរបស់មនុស្សទាំងអស់នៅក្នុងប្រទេសកម្ពុជា ។ ជាការពិតណាស់ កិច្ចសហប្រតិបត្តិការដ៏ជិតស្និទ្ធជាមួយអង្គការក្រៅរដ្ឋាភិបាល ក្រុមសង្គមស៊ីវិល និងស្ថាប័នរដ្ឋាភិបាលនានានឹងត្រូវធ្វើជាបន្តទៅទៀត ។

សភានៃរបបប្រជាធិបតេយ្យទាំងអស់ គឺចាំបាច់ណាស់ ក្នុងការធានាថា សិទ្ធិមនុស្សត្រូវតែបានការពារ ។

ទីមួយ សភាទទួលខុសត្រូវក្នុងការផ្តល់សច្ចាប័ណ្ណដល់សន្ធិសញ្ញា និងអនុសញ្ញាសិទ្ធិមនុស្សអន្តរជាតិ។ ខ្ញុំមានសេចក្តីរីករាយ ដោយបានដឹងថាប្រទេសកម្ពុជាបានផ្តល់សច្ចាប័ណ្ណដល់ឯកសារសិទ្ធិមនុស្សអន្តរជាតិស្នូលទាំង ៦ ។ ក៏ប៉ុន្តែ ខ្ញុំត្រូវលើកឡើងនូវសារៈសំខាន់នៃការដាក់ជូនឱ្យបានទាន់ពេលវេលា នូវរបាយការណ៍ទាំងឡាយជូនទៅអង្គការសន្ធិសញ្ញានានា ។

ខ្ញុំសង្ឃឹមថា ប្រទេសកម្ពុជានឹងពិភាក្សា អំពីការចុះហត្ថលេខា និងការផ្តល់សច្ចាប័ណ្ណ ដល់ពិធីសារស្ម័គ្រចិត្តចំនួន ២ នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ។ ខ្ញុំសូមជំរុញឱ្យផ្តល់សច្ចាប័ណ្ណលើពិធីសារស្ម័គ្រចិត្តនៃអនុសញ្ញាស្តីពីការបំបាត់គ្រប់រូបភាពនៃការរើសអើងប្រឆាំងនារីភេទ ។

សេចក្តីប្រាថ្នាដ៏លើសលុបរបស់យើងខ្ញុំ គឺចង់និយាយអំពីឯកសារសិទ្ធិមនុស្សអន្តរជាតិ "ស្នូល" ចំនួន ៧ ជាជាងចំនួន ៦ ។ អនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិនៃពលករអន្តោប្រវេសន៍ទាំងអស់ និងសមាជិកនៃគ្រួសាររបស់ពួកគេ នឹងចូលជាធរមានភាពជាមួយការផ្តល់សច្ចាប័ណ្ណបន្ថែមមួយទៀត ។ បទបញ្ញត្តិនៃអនុសញ្ញានេះ មានពាក់ព័ន្ធជាមួយប្រទេសកម្ពុជា ហេតុដូច្នេះ ខ្ញុំសូមអំពាវនាវដល់សម្តេច ឯកឧត្តម លោកជំទាវ សូមចុះហត្ថលេខា និងផ្តល់សច្ចាប័ណ្ណ ដល់អនុសញ្ញានេះ ។

ឥឡូវ ចំណុចសំខាន់ គឺការអនុវត្តន៍ និងការដាក់ឱ្យអនុវត្តន៍សន្ធិសញ្ញាទាំងនេះ ។

សមាជិកសភាមានតួនាទីសំខាន់ក្នុងការធានាថារដ្ឋាភិបាល ប្រព្រឹត្តតាមបទដ្ឋានអន្តរជាតិ ដែលមានចែងនៅក្នុងឯកសារសិទ្ធិមនុស្សអន្តរជាតិសំខាន់ ៧ ។

នៅប្រទេសជាច្រើន សភាមានអង្គការសិទ្ធិមនុស្សមួយចេញមកពីសមាជិករបស់ខ្លួន ។ ប្រទេសកម្ពុជា គឺជាគំរូដ៏គួរឱ្យយកចិត្តទុកដាក់មួយ ពីព្រោះសភាទាំង ២ នៃសភារបស់សម្តេច ឯកឧត្តម លោកជំទាវ បានបង្កើតគណៈកម្មការសិទ្ធិមនុស្សរបស់ខ្លួន ។ មុខងារមួយនៃអង្គការសិទ្ធិមនុស្សរបស់សភា គឺពិនិត្យពិច័យច្បាប់ ដើម្បីធានាឱ្យសមស្របទៅតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ។ ខ្ញុំសូមសរសើរចំពោះការងារនេះរបស់គណៈកម្មការសិទ្ធិមនុស្ស និងទទួលពាក្យបណ្តឹង របស់រដ្ឋសភានេះ ។

សម្តេច ឯកឧត្តម លោកជំទាវ

ខ្ញុំសូមលើកឡើងជាមួយ សម្តេច ឯកឧត្តម លោកជំទាវ នូវបញ្ហាមួយ ដែលខ្ញុំដឹងថាជាការព្រួយបារម្ភរបស់យើងទាំងអស់គ្នា ។ នោះគឺការជួញដូរមនុស្សដែលគួរឱ្យស្អប់ខ្ពើម ។ ជារៀងរាល់ថ្ងៃ នៅក្នុងប្រទេសជាច្រើននៃពិភពលោកនេះ ស្ត្រី និងក្មេង ត្រូវបានទិញ និងលក់ ដឹកជញ្ជូន ប្រឆាំងនឹងឆន្ទៈរបស់ពួកគេ ហើយបង្ខំឱ្យចូលទៅក្នុងជីវភាពនៃពេស្យាកម្ម ការថតរូបភាពអាសអាភាស ធ្វើការងារជាទាសករ

និងទុគតិភាពទាំងស្រុង ។ ជីវិតរបស់មនុស្សដ៏អភព្វទាំងនេះ ត្រូវកាត់បន្ថយយ៉ាងខ្លាំងបំផុត ដោយជម្ងឺ និងគ្រោះថ្នាក់ ដែលពួកគេជាកម្មវត្ថុ ។

ជាការគួរឱ្យសោកស្តាយ តំបន់អាស៊ីអគ្នេយ៍ គឺជាមជ្ឈមណ្ឌលដ៏ចំបងមួយ នៃការជួញដូរបែបនេះ។ សម្តេច ឯកឧត្តម លោកជំទាវ នឹងបានជ្រាបថា ជារៀងរាល់ឆ្នាំ ស្ត្រី និងក្មេង ចំនួនជាង ២០០ ០០០ នាក់ ត្រូវបាន "ជួញដូរ" នៅក្នុងតំបន់នេះ ។ នៅតំបន់អាស៊ីអគ្នេយ៍ បញ្ហាជួញដូរ គឺជាភាតុភូតនៃការឆ្លងកាត់ព្រំដែន ។ ប្រទេសកម្ពុជា គឺជាប្រភពមួយ ក៏ដូចប្រទេសឆ្លងកាត់ និងប្រទេសជាអ្នកទទួល។ ក្មេងស្រី និងស្ត្រីវៀតណាម ត្រូវនាំចូលមកកម្ពុជា រីឯក្មេង ស្ត្រី និងបុរសកម្ពុជា ត្រូវបញ្ជូនទៅកាន់ប្រទេសថៃ និងប្រទេសដទៃទៀត ដើម្បីធ្វើការដ៏ថោកទាបបំផុត ។ ប្រទេសកម្ពុជាក៏ប្រឈមមុខជាមួយការជួញដូរមនុស្សក្នុងស្រុកដែរ ។ ចរន្តគឺច្រើនមកពីតំបន់ជនបទឆ្ពោះមកកាន់មជ្ឈមណ្ឌលទីក្រុង តំបន់ទេសចរ និងជិត ៗ ព្រំដែន ។ ភាគច្រើនបំផុតនៃការជួញដូរមនុស្សក្នុងស្រុក គឺសំរាប់ទិសដៅអាជីវកម្មផ្លូវភេទ ការជាប់ពាក់ព័ន្ធនឹងពេស្យាកម្ម ហើយអ្វីដែលជាការព្រួយបារម្ភសំខាន់គឺស្ត្រី និងក្មេង ៗ ។ ក្រុមនៃជនរងគ្រោះជាសក្តានុពលនៅផ្នែកនេះនៃពិភពលោក ក៏ដូចនៅក្នុងផ្នែកដទៃទៀតដែរ គឺការកើនឡើងយ៉ាងលឿន ពីព្រោះមានការរីករាលដាលនៃភាពមិនស្មើគ្នា ការអត់ការងារធ្វើ អំពើហឹង្សា ការរើសអើង និងភាពក្រីក្រ ។ ពួកអ្នករត់ពន្ធមនុស្ស អាចធ្វើប្រតិបត្តិការរបស់ពួកគេ ដោយពុំមានទោសពៃរ៍អ្វីទាំងអស់ ពីព្រោះមកពីការខ្សោយក្នុងការអនុវត្តន៍ច្បាប់ រួមផ្សំជាមួយជាមួយអំពើពុករលួយជាផ្លូវការ ចំពោះករណីខ្លះ ។

តំបន់អាស៊ីអគ្នេយ៍ មិនមែនជាតំបន់តែមួយដែលជំនួញដ៏ថោកទាបនេះ បានកើតមាននោះទេ ។ ថ្មី ៗ នេះ ការសិក្សាមួយ ត្រូវបានបោះពុម្ពផ្សាយ អំពីការជួញដូរមនុស្ស នៅអឺរ៉ុបខាងត្បូង-ខាងកើត ផងដែរ ។ ជំនួញនេះនៅទីនោះ បង្ហាញឱ្យឃើញលក្ខណៈនៃការកេងប្រវ័ញ្ច និងការរំលោភទៅលើស្ត្រី និងក្មេង ៗ ដូចនៅតំបន់នេះដែរ ។ ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស ដោយសហភាគីជាមួយអង្គការ យូនីសេហ្វ និងអង្គការស្តីពីសន្តិសុខ និងសហប្រតិបត្តិការ នៅអឺរ៉ុប បានចាត់ចែងធ្វើការសិក្សាមួយ ។ អង្គការដដែលទាំងនេះ បានធ្វើការជាមួយគ្នា និងជាមួយរដ្ឋាភិបាលនៅក្នុងតំបន់ ដើម្បីបញ្ចប់ការជួញដូរមនុស្សនេះ ។

ចម្លើយមួយផ្អែកទាក់ទិនទៅនឹងច្បាប់តឹងតែងពេក ។ ប្រទេសកម្ពុជាបានចុះហត្ថលេខា កាលពីខែវិច្ឆិកា ឆ្នាំ ២០០១ លើពិធីសារដើម្បីទប់ស្កាត់ បង្ក្រាប និងដាក់ទោស ការជួញដូរមនុស្ស ជាពិសេសស្ត្រី និងក្មេង ៗ បន្ថែមទៅលើអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងឧក្រិដ្ឋកម្មអន្តរជាតិដោយមានការរៀបចំ ។ ខ្ញុំសូមលើកទឹកចិត្ត និងអំពាវនាវ សម្តេច ឯកឧត្តម លោកជំទាវ សូមផ្តល់សច្ចាប័ណ្ណដល់ពិធីសារនេះ ឱ្យបានឆាប់បំផុតដែលអាចធ្វើទៅបាន ។ ខ្ញុំបានកត់សំគាល់ដោយពេញចិត្ត ដែលសភារបស់សម្តេច ឯកឧត្តម លោកជំទាវ បានអនុញ្ញាតផ្តល់សច្ចាប័ណ្ណដល់ពិធីសារស្មគ្រចិត្តលើអនុសញ្ញាស្តីពីសិទ្ធិកុមារ លើការលក់កុមារ ពេស្យាកម្មកុមារ និងការថតរូបភាពអាសអាភាសលើកុមារ ។

ខ្ញុំបានដឹងអំពីការផ្តើមគំនិត និងកម្មវិធីជាច្រើន ដែលប្រទេសកម្ពុជាបានចាត់ឱ្យមានឡើង ដើម្បីទប់ស្កាត់ និងប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស រួមទាំងសហប្រតិបត្តិការជាមួយការិយាល័យយើងខ្ញុំ និងទីភ្នាក់ងារអង្គការសហប្រជាជាតិ និងអន្តរជាតិនានាផង ។ ទាំងនេះគួរត្រូវបានសរសើរទាំងអស់ ។ ប៉ុន្តែ មានសេចក្តីត្រូវការច្រើនទៀតដែលត្រូវធ្វើ ។

កាលពីអាទិត្យមុននេះ ក្រសួងយុត្តិធម៌កម្ពុជាបានបញ្ចប់សេចក្តីព្រាងច្បាប់ពិនិត្យឡើងវិញមួយស្តីពីការជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ។ ខ្ញុំបានអានដោយយកចិត្តទុកដាក់សេចក្តីសង្កេតរបស់ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន លោកជំទាវ មូរ សុខហួរ ក្នុងឱកាសនៃការប្រឹក្សាយោបល់មួយស្តីពីសេចក្តីព្រាងថ្មីមួយ ដែលថាការជួញដូរមនុស្សកំពុងកើនឡើង ហើយកើនឡើងគួរឱ្យព្រួយបារម្ភ ។

ស្ត្រី និងក្មេង ៗ ដែលជាកម្មវត្ថុនៃអំពើឃោរឃៅអមនុស្សធម៌នេះ មិនមានអ្វីចំឡែកចំពោះយើងទេ ។ ពួកគេគឺជាបងប្អូនស្រី និងកូនស្រីរបស់យើង ពួកគេគឺជាកូនរបស់យើង ។ ការជួញដូរមនុស្សនេះ ត្រូវបញ្ឈប់ ។ នៅក្នុងពិភពលោកបច្ចុប្បន្ននេះ ពុំមានកន្លែងសំរាប់វាទេ ។ វាត្រូវតែបញ្ឈប់ បញ្ឈប់ជាស្ថាពរ ។

ថ្ងៃនេះ ខ្ញុំសូមសម្តេច ឯកឧត្តម លោកជំទាវ ធ្វើការជាមួយខ្ញុំ ធ្វើការជាមួយអង្គការសហប្រជាជាតិ និងសហគមន៍អន្តរជាតិ ដើម្បីនាំការជួញដូរមនុស្សទៅកាន់ទីបញ្ចប់ ។

ខ្ញុំសូមចេញផ្សាយនៅថ្ងៃនេះ "សេចក្តីអំពាវនាវនេះ ពីទីក្រុងភ្នំពេញ" ទៅកាន់ប្រទេសទាំងអស់នៅក្នុងតំបន់ ដែលមានសេចក្តីព្រួយបារម្ភចំពោះអ្វី ៗ ដែលនាំឱ្យមានទុក្ខទោស សូមធ្វើការជាមួយគ្នាចាត់ឱ្យមានជំហានដ៏ចាំបាច់និមួយ ៗ កុំទុកជុំថ្មបង្វិលចេញមិនបាន បញ្ចប់ជំនួញដ៏សាហាវ និងអមនុស្សធម៌នេះ ។

ក្នុងក្របខ័ណ្ឌនៃគំរោងការណ៍អន្តរភ្នាក់ងាររបស់អង្គការសហប្រជាជាតិ ស្តីពីការជួញដូរស្ត្រី និងកុមារ នៅក្នុងអនុតំបន់ទន្លេមេគង្គ ខ្ញុំសូមអំពាវនាវដល់រដ្ឋាភិបាលនានា សូមអនុម័តផែនការសកម្មភាពជាតិ ដើម្បីប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ។ ការនេះនឹងពាក់ព័ន្ធដល់ការធានាក្របខ័ណ្ឌច្បាប់មួយដ៏សមស្រប និងការដាក់ឱ្យអនុវត្តនីច្បាប់ដ៏ត្រឹមត្រូវមួយឆ្លើយតបដល់ថ្នាក់ជាតិ ការពារ និងគាំទ្រមនុស្សដែលត្រូវគេយកទៅជួញដូរ កែលំអកិច្ចសហប្រតិបត្តិការ និងការសំរបសំរួលរវាងប្រទេស និងរកឱ្យឃើញ និងឆ្លើយតបទៅនឹងកត្តាទាំងឡាយណាដែលបង្កើនភាពងាយរងទទួលការឈឺចាប់ក្នុងការជួញដូរមនុស្ស និងដែលជំរុញការជួញដូរនេះ។ ខ្ញុំមានសេចក្តីពេញចិត្ត ដោយកត់សំគាល់ឃើញថាប្រទេសកម្ពុជាបានអនុម័តផែនការសកម្មភាពសំរាប់រយៈពេល ៥ ឆ្នាំ មួយ ប្រឆាំងការជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទលើកុមារ ដោយយុទ្ធសាស្ត្រទប់ស្កាត់ ការពារ ព្យាបាលឱ្យជា និងបញ្ចូលមកក្នុងសង្គមវិញ និងថាការទទួលខុសត្រូវដោយឡែកនឹងប្រគល់ឱ្យក្រសួងផ្សេង ៗ ។ វាគឺជាសារៈសំខាន់ណាស់ដែលការចូលជាប់ពាក់ព័ន្ធដូចគ្នានេះ ត្រូវពង្រីកទៅដល់ស្ត្រី និងជនរងគ្រោះដ៏ទៃទៀតនៃការជួញដូរមនុស្សនេះ ។ ឥឡូវ ការខិតខំត្រូវធ្វើទៅលើការពង្រឹងការអនុវត្តនីផែនការ តាមរយៈសកម្មភាពរួមគ្នា នៅកំរិតជាតិ និងកំរិតតំបន់ ។

ការិយាល័យខ្ញុំ បានអភិវឌ្ឍន៍គោលការណ៍ផ្តល់យោបល់ និងគោលការណ៍ណែនាំ ស្តីពីសិទ្ធិមនុស្ស និងការជួញដូរមនុស្ស ដែលខ្ញុំសូមប្រគល់ជូនសម្តេច ឯកឧត្តម លោកជំទាវ ជាសម្ភារៈប្រើប្រាស់ដ៏មានប្រយោជន៍ក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ។ ខ្ញុំមានសេចក្តីពេញចិត្តនឹងប្រកាសថា គោលការណ៍ និងគោលការណ៍ណែនាំទាំងនេះ ត្រូវបានបកប្រែ និងមានជាភាសាខ្មែរហើយ ។ ខ្ញុំសូមអំពាវនាវដល់រដ្ឋសភា សូមធានាថាសេចក្តីព្រាងច្បាប់ថ្មីស្តីពីការជួញដូរមនុស្ស ប្រកាន់យកមូលដ្ឋានត្រឹមត្រូវ និងឆ្លុះបញ្ចាំងឱ្យឃើញកាតព្វកិច្ចសិទ្ធមនុស្សអន្តរជាតិរបស់ប្រទេសកម្ពុជា ក៏ដូចជាគោលការណ៍ និងគោលការណ៍ណែនាំនេះដែរ ។

សិទ្ធិមនុស្ស ត្រូវតែជាស្នូលនៃយុទ្ធសាស្ត្រប្រឆាំងការជួញដូរមនុស្សណាមួយ ដែលគួរឱ្យជឿទុកចិត្តបាន ។ ការដោះស្រាយបញ្ហាសិទ្ធិមនុស្សក៏ទាមទារផងដែរ ឱ្យយើងយល់ដឹងអំពីការទទួលខុសត្រូវរបស់រដ្ឋាភិបាល ក្នុងការការពារ និងការលើកតម្កើងសិទ្ធិរបស់មនុស្សទាំងអស់ស្ថិតនៅក្នុងយុត្តាធិការរបស់ខ្លួន ។ ការទទួលខុសត្រូវនេះត្រូវប្រែឱ្យទៅជាកាតព្វកិច្ចច្បាប់មួយ សំរាប់រដ្ឋាភិបាល ដើម្បីធ្វើការឆ្ពោះទៅលុបបំបាត់ការជួញដូរមនុស្ស និងអាជីវកម្មមានពាក់ព័ន្ធ ។

ប្រព័ន្ធយុត្តិធម៌មួយដែលមានប្រសិទ្ធភាព ដែលយកចិត្តទុកដាក់សមស្របទៅនឹងបញ្ហានៃការជួញដូរមនុស្ស និងទំហំសិទ្ធិមនុស្សរបស់ខ្លួន គឺជាសារៈសំខាន់ណាស់ ដើម្បីធានានូវការទទួលខុសត្រូវរបស់ពួកអ្នកជួញដូរមនុស្ស និងផ្តល់យុត្តិធម៌ដល់ជនរងគ្រោះ ។

កិច្ចខិតខំដើម្បីលើកកំពស់ការយល់ដឹងជាសាធារណៈ គឺសំខាន់ណាស់ ក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ។ យុទ្ធនាការជាប្រពលវប្បកម្មតាមរយៈបណ្តាញផ្សាយពត៌មាន គឺជាការចាំបាច់ ដើម្បីដាស់ស្មារតីប្រជាពលរដ្ឋចំពោះពួកបិសាចមានពាក់ព័ន្ធ ។ តែលើសពីនេះទៅទៀត ត្រូវមានកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ច សំរាប់ស្ត្រី និងកុមារ ដែលអាចមានគ្រោះថ្នាក់ ។ វិធានការការពារបែបនេះ អាចសង្គ្រោះជនរងគ្រោះជាសក្តានុពលបាន ។

ពួកអ្នកដែលអកុសលត្រូវបានយកទៅលក់ដូរ មិនមែនជាឧក្រិដ្ឋជនទេ តែគ្រាន់តែជាជនរងគ្រោះដ៏សាមញ្ញប៉ុណ្ណោះ ។ ពួកគេត្រូវតែផ្តល់ជំនួយឱ្យ ដើម្បីយកជំនះលើភាពទ្រុឌទ្រោម ដែលពួកគេបានឆ្លងកាត់ ក៏ដូចជាជំរើសដ៏ទៃទៀតដើម្បីរស់ក្នុងជីវភាពមួយដ៏សមរម្យ ដែលសិទ្ធិជាមូលដ្ឋានរបស់ពួកគេត្រូវបានគោរព ។ នេះគឺជាការបែងចែកដ៏ច្បាស់មួយ រវាងជនរងគ្រោះនៃការជួញដូរមនុស្ស និងជនអន្តោប្រវេសន៍ខុសច្បាប់ដែលមិនត្រូវមានការយល់ច្រឡំ ។

ខ្ញុំគ្រាន់តែចង់និយាយថា ខ្ញុំមានសេចក្តីសោកស្តាយចំពោះសេចក្តីសំរេចរបស់តុលាការកម្ពុជា កាលពីថ្ងៃទី ៥ ខែសីហាកន្លងទៅនេះ ដែលបានចោទប្រកាន់ជនរងគ្រោះនៃការជួញដូរមនុស្ស ថាជាជនអន្តោប្រវេសន៍ខុសច្បាប់ ហើយកាត់ទោសឱ្យពួកគេជាប់គុក ។

ឆន្ទៈនយោបាយម៉ឺងម៉ាត់ និងជាប់ជាបន្ត ដើម្បីកំទេចចក្រនៃការជួញដូរមនុស្ស ត្រូវតែជាសកម្មភាពជាជន្ទល់ នៅក្នុងវិស័យខាងលើទាំងអស់ ។

សម្តេច ឯកឧត្តម លោកជំទាវ

នៅក្នុងប៉ុន្មានអាទិត្យខាងមុខនេះ ខ្ញុំនឹងចាកចេញពីការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស និងវិលត្រឡប់ទៅកាន់ជីវិតឯកជនវិញ ។ ខ្ញុំមានមនៈសិការណាស់អំពីការសោកល្បងជាបន្ត ក្នុងការធានាការគោរពចំពោះសិទ្ធិ នៅទូទាំងពិភពលោកយើងនេះ ។ តែនៅក្នុងពេលជាមួយគ្នានេះ ខ្ញុំមានការលើកទឹកចិត្តដោយការដែលពិភពលោក បានដោះស្រាយបញ្ហានេះដោយហ្មត់ចត់ និងដោយខ្លាំងក្លាជាងកាលពីពេលអតីតកាល ។

ជាផ្ទាល់ខ្លួន ខ្ញុំនឹងស្ថិតនៅសកម្មក្នុងការបន្តការខិតខំ ដើម្បីធានាការគោរពចំពោះសិទ្ធិមនុស្ស ។ ខ្ញុំនឹងត្រៀមខ្លួនជានិច្ច ដើម្បីធ្វើអ្វី ១ ដែលខ្ញុំអាចធ្វើទៅបាន ដើម្បីជំនះលើការទប់ទល់ ឬការស្ទាក់ស្ទើរ និងដើម្បីឈានទៅមុខនូវការគោរពជាសកលចំពោះសិទ្ធិមនុស្ស ។

សម្តេច ឯកឧត្តម លោកជំទាវ

ខ្ញុំសូមអរគុណជាថ្មីម្តងទៀត ចំពោះការទទួលដ៏កក់ក្តៅ ពីសំណាក់សម្តេច ឯកឧត្តម លោកជំទាវ។ ខ្ញុំសូមប្រសិទ្ធិពរចំពោះសម្តេច ឯកឧត្តម លោកជំទាវ និងប្រជាពលរដ្ឋកម្ពុជា ដែលសម្តេច ឯកឧត្តម លោកជំទាវ ជាតំណាង សូមជួបប្រទះតែសន្តិភាព និងសុភមង្គល ដែលប្រទេសនេះត្រូវតែទទួលបានដ៏ជ្រាលជ្រៅ ។

សូមអរគុណ ។

<u>ការបកប្រែសំរួលពីអត្ថបទដើមជាភាសាអង់គ្លេស</u>